មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0184

# សម្ភាសន៍ជាមួយឈ្មោះ ឈុន និប ភេទស្រី អាយុ៦១ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ កងនារីចល័ត

## សព្វថ្ងៃរស់នៅភូមិប៉ុស្តិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ វ៉ាន់ ថាន់ ពៅដារ៉ា

០០:៣៨:៤៤

១២ទំព័រ

ពៅដារ៉ា ៖ មីងឈ្មោះអី?

និប ៖ ឈុន និប ។

ពៅដារ៉ា ៖ អាយុប៉ុន្មានឆ្នាំហើយ?

និប ៖ ៦១ ។

ពៅដារ៉ា ៖ ស្រុកកំណើតនៅណា?

និប ៖ នៅភូមិប៉ុស្តិ៍ចាស់ ។

ពៅដារ៉ា ៖ ឃុំ?

និប ៖ ឃុំព្រះនេត្រព្រះ ។

ពៅដារ៉ា ៖ ស្រុក?

និប ៖ ព្រះនេត្រព្រះ ។

ពៅដារ៉ា ៖ ខេត្តបន្ទាយមានជ័យ?

និប ៖ ចាស៎!

ពៅដារ៉ា ៖ ឥលូវមីងរស់នៅក្នុងភូមិដដែល?

និប ៖ ចាស៎!

ពៅដារ៉ា ៖ អត់មានផ្លាស់ប្តូរអីទេ?

និប ៖ អត់ទេ ។ ជម្លៀសតែសម័យអាពត ។

ពៅដារ៉ា ៖ មីងមានគ្រួសារឈ្មោះអីដែរ?

និប ៖ នៅរស់ជាមួយគ្នាសព្វថ្ងៃឈ្មោះហ៊ួម យ៉ុង ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ពៅដារ៉ា ៖ គាត់អាយុប៉ុន្មានឆ្នាំដែរ?

និប ៖ ទើប៥៨ ។

ពៅដារ៉ា ៖ គាត់ធ្វើអីសព្វថ្ងៃ?

និប ៖ ធ្វើស្រែ ។

ពៅដារ៉ា ៖ មានកូនចៅប៉ុន្មាននាក់ដែរ?

និប ៖ កូន០៤នាក់ ។

ពៅដារ៉ា ៖ ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

និប ៖ ប្រុស០២ ស្រី០២ ។

ពៅដារ៉ា ៖ មីងមានបងប្អូនប៉ុន្មាននាក់?

និប ៖ ០៤នាក់ ។

ពៅដារ៉ា ៖ ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

និប ៖ ប្រុស០២ ស្រី០២ ។

ពៅដារ៉ា ៖ នៅរស់ទាំងអស់?

និប ៖ បងប្អូនខ្ញុំនៅរស់ទាំងអស់ ។

ពៅដារ៉ា ៖ ចុះឪពុកម្តាយមីង?

និប ៖ ឈុន គក់ ។ ស្លាប់នៅសម័យប៉ុល ពត ។

ពៅដារ៉ា ៖ ចុះម្តាយ?

និប ៖ ឡូប ពិក ។

ពៅដារ៉ា ៖ ឪពុកអ៊ីស្លាប់ក្នុងសម័យប៉ុល ពតហ្នឹង ស្លាប់ម៉េចទៅ?

និប ៖ ដោយគេយកទៅសម្លាប់ ។

ពៅដារ៉ា ៖ គេហ្នឹងអ្នកណា?

និប ៖ មិនស្គាល់គេទេ ដោយយប់អាធ្រាធ ។ ខ្ញុំទៅចល័តបាត់ ហើយគាត់នៅជាមួយម្តាយខ្ញុំ ហើយម្តាយខ្ញុំគាត់ខ្វាក់ ។

ពៅដារ៉ា ៖ ឪពុកហ្នឹងអី?

និប ៖ ម្តាយខ្ញុំខ្វាក់ ឪពុកមិនខ្វាក់ទេ ។

ពៅដារ៉ា ៖ យកទៅពេលពួកប៉ុល ពត ចូលក្នុងសម័យ៧៥ហ្នឹងអី?

និប ៖ មិនដឹងប៉ុន្មានទេ ។ យកទៅបាន០៦ ០៧ខែក៏ចប់ ។

ពៅដារ៉ា ៖ គាត់មានកំហុសអី?

និប ៖ កំហុសហូបមិនឆ្អែតហ្នឹងឯង ។

ពៅដារ៉ា ៖ គាត់និយាយ?

និប ៖ ចាស៎! និយាយទៅក៏គេស្អប់យើង ហូបមិនបានគ្រប់គ្រាន់មិនឆ្អែតគាត់ថា ។

ពៅដារ៉ា ៖ និយាយហូបមិនឆ្អែត?

និប ៖ ហូបបបររាវក្លោក ។ បើសម្រឹតយកទឹកប្រហែលជា០ ១ស្លាបព្រាហ្នឹងកាក់បបរ ។

ពៅដារ៉ា ៖ អញ្ចឹងដោយសារគាត់និយាយហូបមិនឆ្អែតអីអញ្ចឹង គេយកគាត់ទៅសម្លាប់?

និប ៖ ចាស៎!

ពៅដារ៉ា ៖ គាត់អត់មានធ្វើជាទាហានអីទេ?

និប ៖ អត់មានជាប់ប្រវត្តិទេ ។

ពៅដារ៉ា ៖ កាលហ្នឹងក្នុងភូមិមមីងអ្នកណាជាប្រធានភូមិ?

និប ៖ កាលហ្នឹងគេជម្លៀសខ្ញុំទៅនៅក្រុមជាល ខ្ញុំភ្លេចអស់ហើយ ។

ពៅដារ៉ា ៖ គេឲ្យទៅនៅក្រុមអីគេ?

និប ៖ ក្រុមជាល ។

ពៅដារ៉ា ៖ សម្រាប់ធ្វើអីក្រុមហ្នឹង?

និប ៖ កាលនោះខ្ញុំធ្វើចម្ការបន្តិចបន្តួច គាត់ចាស់ជរាក៏គាត់មើលចៅមើលអីទៅម្ដាយខ្ញុំ ហើយ ពួកទៅចល័តបាត់ ។

ពៅដារ៉ា ៖ អញ្ចឹងនិយាយមិញហ្នឹងឪពុកមីងទេអីដែលគេឲ្យទៅនៅក្រុមជាល?

និប ៖ ចាស៎!

ពៅដារ៉ា ៖ ក្រុមជាលហ្នឹងគេចម្ការអីហ្នឹង?

និប ៖ ចាស៎!

ពៅដារ៉ា ៖ ចុះសម្រាប់មីងផ្ទាល់?

និប ៖ ខ្ញុំទៅចល័ត ។

ពៅដារ៉ា ៖ គេហៅចល័តអី?

និប ៖ ចល័តច្រើន ។ ជួនកាលចល័តទៅប្រឡាយត្រពាំងថ្ម ពីភ្នំស្រុកទៅ ។

ពៅដារ៉ា ៖ ចល័តនេះចល័តកុមារឬក៏?

និប ៖ ចល័តនារី ។

ពៅដារ៉ា ៖ មីងចល័តនារីចល័តស្រុកឬក៏ចល័តតំបន់កាលហ្នឹង?

និប ៖ កាលនោះខ្ញុំចល័តតំបន់ ។

ពៅដារ៉ា ៖ អ្នកណាគ្រប់គ្រងចល័តតំបន់ហ្នឹង?

និប ៖ ខ្ញុំភ្លេចអស់ហើយ ។

ពៅដារ៉ា ៖ អត់ស្គាល់អ្នកគ្រប់គ្រង?

និប ៖ ទេ ។ កាលនោះសុទ្ធតែពួកនិរតីប្រធានកងធំ ។

ពៅដារ៉ា ៖ មីងទៅប្រហែលជាឆ្នាំប៉ុន្មានទៅ?

និប ៖ មិនដឹងជាឆ្នាំ៧០ប៉ុន្មានទេ ខ្ញុំទៅត្រឡប់មកវិញបានសម្ភារបានពួកឃ្មួនចូល ។

ពៅដារ៉ា ៖ មិងទៅបានប៉ុន្មានខែទៅ?

និប ៖ វាចល័តច្រើនចល័តទៅនេះខ្លះទៅនោះទៅថ្មពួក ខាងសាលាក្រហមខ្លះ ។

ពៅដារ៉ា ៖ មីងរៀបរាប់មើលមីងចល័តនេះមុនដំបូងមីងទៅកន្លែងណាខ្លះ?

និប ៖ ទៅចល័តអូរលៀសខាងត្រពាំងថ្ម ។

ពៅដារ៉ា ៖ នៅអូរលៀស?

និប ៖ ចាស៎!

ពៅដារ៉ា ៖ នៅហ្នឹងធ្វើអីខ្លះ?

និប ៖ មុនដំបូងខ្ញុំរែកដី លើកទំបន់ ។

ពៅដារ៉ា ៖ រែកដី លើកទំបន់?

និប ៖ ចាស៎! ០១ថ្ងៃ០១ម៉ែត្រគីប ។

ពៅដារ៉ា ៖ ០១ថ្ងៃ ០១ម៉ែត្រគីប?

និប ៖ បានយូរដែរប្រហែលកន្លះខែអីគេឡើងឲ្យ០១ថ្ងៃ០១ម៉ែត្រគីបកន្លះ រហូតមកដល់ ០១ថ្ងៃ០២ម៉ែត្រគិបទៀតខ្ញុំស៊ូមិនបាន ។ ហើយហូបតែបបរហ្នឹងមិនដែលមានអីហូបទេ ។

ពៅដារ៉ា ៖ ហ្នឹងនៅត្រពាំងថ្ម?

និប ៖ ចាស៎!

ពៅដារ៉ា ៖ លើកនៅហ្នឹងក្នុងកងចល័តនារីតំបន់ដដែល?

និប ៖ ចាស៎!

ពៅដារ៉ា ៖ អ្នកណាគេជាប្រធានកងចល័តនារីហ្នឹង?

និប ៖ កងធំសុទ្ធតែពួកនិរតី ។

ពៅដារ៉ា ៖ ស្គាល់ឈ្មោះទេ?

និប ៖ មិនស្គាល់ទេ គេទៅខាងនោះអស់ហើយដល់ជិតចប់សន្តិភាពហើយគេទៅខាងបន្ទាយអំពិល គេបបួលពួកខ្ញុំទៅឲ្យទៅចូលខាងគេ ដល់ខ្ញុំអត់ទៅ ខ្ញុំក៏គេចមកវិញ ។

ពៅដារ៉ា ៖ ទៅបន្ទាយអំពិល?

និប ៖ ចាស៎!

ពៅដារ៉ា ៖ មីងសុំអត់ទៅបានដែរ?

និប ៖ បាន ៗ ខ្ញុំមិនទៅ បើអ្នកណាស្មោះទៅគេយកទៅ ។

ពៅដារ៉ា ៖ ទៅលើកទំបន់ហ្នឹងកងមីងមានប៉ុន្មាននាក់?

និប ៖ មាកងតូចខ្ញុំមាន៣០នាក់ បើកងធំមាន១០០នាក់ បើក្រុមខ្ញុំមាន១០នាក់ ។

ពៅដារ៉ា ៖ អញ្ចឹងមីងនៅកងតូច?

និប ៖ ចាស៎!

ពៅដារ៉ា ៖ ប្រធានក្រុមមីងឈ្មោះអីទៅ?

និប ៖ មីងមិញនៅនេះៗ វាល្អទេមិនអីទេ យ៉ាប់តែពួកនិរតីទេ ។ ហូបមិនឆ្អែតទេ បានអីញ៉ាំគេ ហូបតែខ្លួនគេទេ ចំពោះយើងគេឲ្យហូបតែបបររាវ ។

ពៅដារ៉ា ៖ អ្នកដែលទៅជាមួយមីង មីងមានស្គាល់អ្នកណាខ្លះ?

និប ៖ មីងអង្គុយនៅនេះមួយ ។

ពៅដារ៉ា ៖ ឈ្មោះអីគេ?

និប ៖ ឈ្មោះណោង នាងខាងនោះឈ្មោះយ៉ក សម្បត្តិ ។

ពៅដារ៉ា ៖ ហើយអ្នកណាទៀត?

និប ៖ ខ្ញុំភ្លេចអស់ហើយ ។

ពៅដារ៉ា ៖ មីងយ៉ក សម្បត្តិហ្នឹងជាកូនក្រុមដូចមីងដែរ?

និប ៖ ជាកូនក្រុមមិនមែនប្រធានតែ ។

ពៅដារ៉ា ៖ ការហូបចុកម៉េចវិញ?

និប ៖ មិនដែលបានគ្រប់គ្រាន់ទេ សូម្បីតែសម្លក៏មិនមានប្រហុកបង់ផង ។ សុំតែអំបិលគេក៏គេ មិនឲ្យ គេថាសម្លគេដាក់អំបិលហើយគេមិនឲ្យទេ ។ គេថា យើងចង់ញ៉ាំតែយើង ។ ដូចថា សម្លបន្លែប្រាចក៏យើងមិនដែលស្គាល់ប្រាចហ្នឹងម៉េចដែរ ប្រវ៉ាទូកយកមកហាន់សូម្បីតែ ជ្រូកសព្វថ្ងៃក៏វាមិនហូបទេ ។ យើងមិនហ៊ាននិយាយតវ៉ាទេ បើយើងនិយាយសុទ្ធតែយើង

ហ្នឹងកម្មសិទ្ធិក្រាស់ ស្ដីសុទ្ធតែយើងហ្នឹងនាយទុន យើងមិនហ៊ាននិយាយទេ បើយើងនិយាយគេយកទៅសម្លាប់ចោល ដល់អញ្ចឹងចេះតែស៊ូៗដល់ខ្ញុំស៊ូមិនបាន ខ្ញុំចេញមកនៅព្រៃមាន់ទៅ អាប្រឡាយព្រៃមាន់យើងហ្នឹង លើកមកទល់នឹងចុប អាហ្នឹងនៅខែកក្ដិក។ អាខ្យល់ខែកក្ដិកបក់មកពីជើង ហើយក៏ចុះទឹកបាស្មោបិទទំបន់អញ្ចែស ធ្វើប្រឡាយអញ្ចែសបានទាំងព្រឹក ខ្ញុំស៊ូមិនបាន។ និយាយមិនលាក់បាំងអីទេ ខ្ញុំត្រូវត្រដាក់អញ្ចឹងក៏រាំងខែថ្ងៃ០៧ខែ។ ដល់ខ្ញុំអត់រដូវអញ្ចឹងសាច់ខ្ញុំក៏ស្វែកស្វាងក៏ឈឺទារុណទារាទៅ ខ្ញុំក៏សុំគេទៅសម្រាលពេទ្យនៅស្វាយ ហើយសម្រាលពេទ្យជិត០១ខែដែរ តែអត់ជាទេ។ រហូតខ្ញុំត្រឡប់មកភូមិវិញ ខ្ញុំក៏រកថ្នាំខ្មែរតាមសង្គមកិច្ចដើមគេមិនហៅពេទ្យទេ គេហៅសង្គមកិច្ចគេក៏ស្ងោរថ្នាំខ្មែរទៅហូបទៅក៏បានដើររដូវវិញទៅ ហើយក៏មានជាគ្រួសារអញ្ចឹងទៅក៏មកនៅក្នុងភូមិជាមួយឪពុកម្ដាយ ។

ពៅដារ៉ា : នៅភូមិណា?

និប : ក្នុងភូមិប៉ីយតឿង ។

ពៅដារ៉ា : កាលហ្នឹងអ្នកណានៅភូមិណាពួកប៉ុល ពត មិនឲ្យនៅភូមិរបស់យើងទេ?

និប : ចាស៎! ពីដើមខ្ញុំនៅភូមិនេះឯង។ ដល់ជម្លៀសទៅគេឲ្យទៅនៅចុប ដល់ត្រលប់ពីចុបវិញខ្ញុំនៅក្រុមផាល ត្រលប់ទៅពីក្រុមផាលវិញខ្ញុំមកនៅប៉ីយតឿង ។

ពៅដារ៉ា : ប៉ីយតឿងហ្នឹងចុងក្រោយគេ?

និប : ចាស៎!

ពៅដារ៉ា : ពេលមកដល់ភូមិគេឲ្យមីងធ្វើអី?

និប : គេឲ្យយើងធ្វើការជាមួយវ័យកណ្ដាល ប្រូតស្រូវដាក់សហករណ៍ ឲ្យយើងធ្វើចម្ការ តែគេឲ្យយើងហូបចុកតែបបរហ្នឹងឯង ។

ពៅដារ៉ា : ពេលមកភូមិវិញមិនដែលស្គាល់ហូបបាយទេ?

និប : មិនដែលទេ មិនដឹងថារសជាតិបាយហ្នឹងមានរសជាតិយ៉ាងណាវាចង់ភ្លេចអស់ហើយ ។ សូម្បីតែខ្ញុំស្គមអញ្ចឹងក៏អត់មានសាច់ដោះទេ ស្បែកដណ្ដប់ឆ្អឹង ។

ពៅដារ៉ា : កាលវែកដីនៅត្រពាំងថ្មហ្នឹងមានហូបបាយអីទេ?

និប : អត់ទេ យ៉ាងច្រើណាស់ហូបបានតែបបរខាប់ទេ មិនបានបាយរឹងទេ ។

ពៅដារ៉ា : លើកនៅមាត់មុំណាខ្លះនៅត្រពាំងថ្ម?

និប : លើកនៅត្រពាំងថ្មបាន០១ខែ ខ្ញុំក៏ត្រលប់មកលើកនៅប្រឡាយព្រៃមាន់នេះឯង ។

ពៅដារ៉ា ៖ ខ្ញុំបានសួរនាំខ្លះដែរ ក្រុមខ្លះនៅត្រពាំងថ្មហ្នឹងមានបានហូបបាយខ្លះដែរ?

និប ៖ អ្នកហូបបាយទាល់តែគេទៅខាងជើងនាំងយ៉ក សម្បត្តិនេះគេទៅខាងជើងគេបានហូបបាយ ហើយខ្ញុំនៅខាងត្បូងខាងនេះ ។

ពៅដារ៉ា ៖ ខាងត្បូងមោ?

និប ៖ ចាប់ពីភ្នំស្រុកមកត្បូងលើកប្រឡាយទល់ៗគ្នាគេនៅខាងជើង ។

ពៅដារ៉ា ៖ មានពេលសម្រាលទេ?

និប ៖ សម្រាលតែពេលហូបបាយ ។

ពៅដារ៉ា ៖ ម៉ោងប៉ុន្មានហូបបាយ?

និប ៖ ម៉ោង១១ៈ០០ ហូបបាយ ។

ពៅដារ៉ា ៖ ប៉ុន្មានពេលក្នុង០១ថ្ងៃ?

និប ៖ ហូបតែ០១ពេលទេល្ងាច ។

ពៅដារ៉ា ៖ ចុះល្ងាចឡើង?

និប ៖ ល្ងាចឡើងមកវិញម៉ោង០៦ៈ០០ក៏ហូប ។

ពៅដារ៉ា ៖ អញ្ចឹង០២ដង?

និប ៖ ចាស៎!

ពៅដារ៉ា ៖ មានធ្វើបន្ថែមនៅពេលយប់ទេ?

និប ៖ បើធ្វើបន្ថែមពេលយប់យើងដកសំណាបក្នុង០១ថ្ងៃគេឲ្យយើងដក ០២ដួន ០៣ដួនឬក៏ ០៤ដួនតាមសំណាបដកស្រួលឬក៏សំណាបដកយ៉ាប់ ។ បើយើងដកថ្ងៃបាន០៣ដួនហូបបាយល្ងាចម៉ោង០៧ៈ០០យប់គេឲ្យយើងទៅដក០១ដួនទៀត ។

ពៅដារ៉ា ៖ ពេលនិយាយនេះមីងនៅដាល?

និប ៖ អត់ទេ នៅមុខព្រួញ ។

ពៅដារ៉ា ៖ នៅត្រពាំងថ្មហ្នឹង?

និប ៖ អត់ទេ នៅទំបន់អូរលៀស ។

ពៅដារ៉ា ៖ នៅត្រពាំងថ្មមីងធ្វើអីខ្លះ?

និប ៖ រែកតែដីហ្នឹង ។

ពៅដារ៉ា ៖ រែកដល់ម៉ោងប៉ុន្មានយប់ទៅ?

និប ៖ បើគេប្រើ០១មែត្រគីប បើរួចក៏រួចទៅមិនបានធ្វើយប់ទេ បើយើងមិនរួចក៏យប់ទៀត ។

ពៅដារ៉ា ៖ ហ្នឹងគេកំណត់ឲ្យ?

និប ៖ ចាស៎!

ពៅដារ៉ា ៖ ដីវែងទន់ម៉េចទៅ?

និប ៖ ដីស្រែដូនកាលគេភ្ជួរជាអាត្រាកទៅក៏ស្រួលទៅ បើគេមិនភ្ជួរឲ្យទៅដីក៏មិនសូវរឹងប៉ុន្មានទេ ដីល្បាយខ្សាច់មិនសូវអីទេ ។

ពៅដារ៉ា ៖ កាលទៅលើកដីនៅត្រពាំងថ្មហ្នឹងទៅនៅណាទៅ?

និប ៖ នៅការដ្ឋាននៅតាមវាល បើអ្នកណាមានកៅស៊ូក៏យកបាំងទៅ បើអត់មានក៏ហាលវាលទៅ បើអ្នកណាមានស្បូវក៏យកប្រ៉កទៅ ភ្លៀងយប់ទៅទទឹកក៏ទទឹកទៅ ។

ពៅដារ៉ា ៖ មានចំខែភ្លៀងដែរ?

និប ៖ មាន ។

ពៅដារ៉ា ៖ អញ្ចឹងសំពត់អត់កើត?

និប ៖ អត់កើតទេ ភ្លឺឡើងទៅធ្វើការទៀត ។

ពៅដារ៉ា ៖ គ្រប់គ្នាអញ្ចឹង?

និប ៖ គ្រប់គ្នាឲ្យតែប្រជាជន លើកលែងតែប្រធានៗ ។ ប្រធានគេមានសឹស័ក្តខ្ទមប៉ុណ្ណេះៗដាំចង់អង្រឹងពួកយោធាអីហ្នឹង ។

ពៅដារ៉ា ៖ ចុះទឹកអីមានគ្រប់គ្រាន់ទេ?

និប ៖ បើនិយាយពីអត់ ផ្ទួតទឹកយ៉ាប់បន្តិចហើយមិនសូវមានទេ ទឹកហូបហ្នឹងក៏កក្រិច ។

ពៅដារ៉ា ៖ ទឹកម៉េច?

និប ៖ ទឹកល្អក់ ។

ពៅដារ៉ា ៖ អត់មានគេចែកទឹកទេអី?

និប ៖ មិនមានគេចែកទឹកទេ ។ ការងាររួចក៏យើងទៅរកខ្លួនឯងទៅបាន០៣ ០៤លីត្រយើងក៏ទុកទៅមាហូបទៅ បបរគេដាំចែក ។

ពៅដារ៉ា ៖ ប៉ុន្មានថ្ងៃបានៗផ្ទួតទឹកម្តង?

និប ៖ ផ្ទួតរាល់ថ្ងៃរួចពីការងារហើយទៅផ្ទួតទៅ ។

ពៅដារ៉ា ៖ ហ្នឹងនៅខែប្រាំង?

និប ៖ ខែប្រាំង ។

ពៅដារ៉ា ៖ ចុះបើខែភ្លៀងវិញ?

និប ៈ បើខែភ្លៀងមានហូបបបូរ ។

ពៅដារ៉ា ៈ នៅត្រពាំងថ្មមីងនៅបានរយៈពេលប៉ុន្មាន?

និប ៈ ប្រហែលជា០១ខែ ហើយខ្ញុំស៊ូវែកដីមិនបានក៏ខ្ញុំដកខ្លួនចេញទៅ ។

ពៅដារ៉ា ៈ មីងមានសុំប្រធានគេទេ?

និប ៈ ខ្ញុំសុំប្រធាន ។

ពៅដារ៉ា ៈ ប្រធានហ្នឹងឈ្មោះអី?

និប ៈ ខ្ញុំមិនបានស្គាល់គេទេ ។ ប្រធានគេហ្នឹងមិនមែនអ្នកនៅស្រុកនេះទេ ហើយប្រជាជនមូលដ្ឋានចាស់មិនមែនយកទេ គេយកតែប្រធានដែលមកពីណានោះ ។

ពៅដារ៉ា ៈ ប្រាប់ប្រធានថាម៉េចបានគេឲ្យទៅ?

និប ៈ ខ្ញុំសុំថា ខ្ញុំឈឺត្រគាកណាស់ខ្ញុំវែកដីមិនបានទេ ។ បើមិត្តឯងវែកមិនបាន ជូនមិត្តឯងទៅលើកទំបន់ខាងនោះទៅ ទំបន់នោះមិនពិបាកលើកទេនៅទំបន់ព្រៃមាន់ហ្នឹង ។ ដល់ខ្ញុំបាត់រដូវអញ្ចឹងខ្ញុំក៏ទៅពេទ្យនៅស្វាយហ្នឹង ហើយដល់ក្រោយមោខ្ញុំមកនៅជាមួយប្រជាជនក្នុងភូមិក៏ចប់ប៉ុណ្ណឹងឯង ។

ពៅដារ៉ា ៈ នៅពេទ្យហ្នឹងមានឲ្យថ្នាំអីត្រឹមត្រូវទេ?

និប ៈ ថ្នាំមានគេចម្រាញ់ចេញពីឬសឈើ ហើយហូបមិនមានប្រសិទ្ធិភាពអីទេអាថ្នាំអាចម៍ទន្សាយហ្នឹង ។ ដេកនៅពេទ្យហ្នឹងគេឲ្យបាយដែរ តែបាយជាយស្វាគេចែកជារបបបើសម្លគេមានបន្លែស្ពី ត្រីកន្ទុសលាយទៅ ។

ពៅដារ៉ា ៈ ទៅដេកពេទ្យហ្នឹងប៉ុន្មានថ្ងៃទៅ?

និប ៈ យូរដែរបានប្រហែលជា២០ថ្ងៃដែរ ។ ខ្ញុំសុំគេទៅគេមិនធ្វើទេសនាមឲ្យខ្ញុំមកភូមិទេ គេធ្វើទេសនាមឲ្យខ្ញុំទៅមុខព្រួញវិញ ដល់ខ្ញុំមិនទៅខ្ញុំចូលមកឪខ្ញុំហ្នឹង ។

ពៅដារ៉ា ៈ ចូលម៉េចបានទៅ?

និប ៈ លួចចូលមកៗទៅកូនឈ្លបគេតាម ។ គេថា មិត្តឯងទៅណា? ខ្ញុំថា ខ្ញុំទៅភូមិខ្ញុំមិនស្រួលទៅរកថ្នាំខ្មែរផឹកសិន ក៏គេឲ្យមោទៅ ។ ដល់ខ្ញុំមកភូមិខ្ញុំក៏សុំប្រធានសហករណ៍នៅ ខ្ញុំថា ខ្ញុំទៅវែកដីនៅទំបន់មិនបាន ខ្ញុំសុំនៅធ្វើការក្នុងភូមិជាមួយម៉ែពុក ។ គេឲ្យនៅទៀ ហើយគេចុះខ្ញុំជាវ័យកណ្តាលកាលនោះ ។

ពៅដារ៉ា ៈ ពេលមីងសុំអញ្ចឹងគេមិនសួរនាំបញ្ជាក់ពីពេទ្យអីទេ?

និប ៖ គេសួរថា មិត្តឯងទៅដេកពេទ្យហ្នឹងមានបាត់ទេ ។ ខ្ញុំថា មិនបាត់ទេខ្ញុំរាំងរដូវសុំនៅជាមួយម៉ែពុកអញ្ចឹងទៅក៏គេឲ្យនៅ ។ ប៉ុនថា ឲ្យនៅយើងធ្វើការជាមួយវ័យកណ្ដាលធ្វើចម្ការច្រូតស្រូវដាក់តាមសហករណ៍ទៅ របបនៅក្នុងភូមិនេះវាអត់ខ្លាំងជាងនៅមុខព្រួញទៀត ។

ពៅដារ៉ា ៖ នៅជាមួយឪពុកម្ដាយបានយូរទេ?

និប ៖ បានជិត០១ឆ្នាំ ។

ពៅដារ៉ា ៖ នៅរហូតដល់ពេលបែក?

និប ៖ ចាស៎!

ពៅដារ៉ា ៖ នៅសហករណ៍ហ្នឹងគេហៅសហករណ៍អី?

និប ៖ សហករណ៍ភូមិប៉័យក្តៀង ។

ពៅដារ៉ា ៖ អ្នកប្រធានសហករណ៍?

និប ៖ តាឈួង គាត់ស្លាប់ហើយ ។ ទោះបីតែកូនចៅក៏មិនសល់ គេសម្លាប់ចោល ។ ពួកណាទេជិតវៀតណាមចូល វិរបបស្លាប់អស់សូម្បីតែប្រធានសហករណ៍ ប្រធានពួកនេះក៏វាធ្វើបាប ។

ពៅដារ៉ា ៖ វៀតណាមអ្នកសសម្លាប់?

និប ៖ ទេមិនមែនពួកវៀតណាមទេ មិនដឹងពួកណាទេកាលនោះ ។

ពៅដារ៉ា ៖ ប្រធានសហករណ៍តាឈួង?

និប ៖ តាឈួង គាត់ចិត្តល្អទេ ។

ពៅដារ៉ា ៖ គេសម្លាប់មុនបែកឬក៏សម្លាប់ក្រោយបែក?

និប ៖ ក្រោយរបបដួចជាគេចម្រាញ់ពួកណាជាប់ប្រវត្តិទាហានបាន០១ថ្ងៃក្ដី ០១ខែក្ដី ០១ឆ្នាំក្ដីសម្លាប់អស់ដល់មកពយកនេះ ។

ពៅដារ៉ា ៖ ប្រហែលជាឆ្នាំណា?

និប ៖ មិនដឹងឆ្នាំណាទេជិតចប់ហើយ ។

ពៅដារ៉ា ៖ ពេលមីងនៅសហករណ៍ហ្នឹងការហូបចុកអីហ្នឹងម៉េចដែរ?

និប ៖ យ៉ាប់ណាស់ ។

ពៅដារ៉ា ៖ ធ្វើម៉េចអាចរស់រានបាន?

និប ៖ ដោយសារស្លឹកឈើ ត្រកួន ប្រលឹត មានបងប្អូនទៅវាលអញ្ចឹងទៅបានត្រកួនមោយើងហាន់យកទៅស្រុះលាយជាមួយអង្ករ០១គ្រាប់ៗ ។ ជួនកាលបានគល់ចេក គល់ល្ហុងចេះ

តែហូបទៅ ជាពិសេសល្ហុងយកមកឆុសពូតយកទឹកវាចេញបានយកអំបិលមកចម្រាច់វាចេញ ហើយក៏មានអង្ករ០១គ្រាប់យើងដួសដាំបាយ ។

ពៅដារ៉ា ៖ ហូបបាន?

និប ៖ ចេះតែហូបទៅទ្រួយសាវម៉ាវ ទ្រួយដំឡូងមី ទ្រួយដំឡូងជ្វាអីហូបទាំងអស់ ។

ពៅដារ៉ា ៖ មីងបានគ្រួសារនៅឆ្នាំណា?

និប ៖ ចប់អាពត ភ្លាមម្ដាយខ្ញុំឲ្យ បងប្អូនខ្ញុំឲ្យមកដណ្ដឹងខ្ញុំមិនទាន់មានម្សៅអីហូបទេ ពេលខ្ញុំបានគ្រួសារអត់ទាន់មានសម្ល ម្សៅស៊ុបទេ ។ គ្រួសារខ្ញុំភូមិកំណើតគាត់នៅភូមិបឹងវែង មិនមែននៅភូមិនេះជាមួយគ្នាទេ ហើយក៏មិនដែលឃើញគ្នាដែរ ។

ពៅដារ៉ា ៖ កូនចៅមីងរបររកស៊ីអីខ្លះទៅ?

និប ៖ កូនខ្ញុំមួយបានប្រពន្ធទៅនៅចានោមនោះក្រណាស់មិនមានអីទេ ។ មុនដំបូងខ្ញុំឲ្យទៅនៅស្វាយរៀនជាងមាសហេតុតែគ្មានវាសនា ទ្រាំនឹងជាងមាសមិនរួចក៏ត្រលប់មកវិញក៏គេឃើញគ្នានៅស្វាយក៏គេស្រលាញ់គ្នា ហើយខ្ញុំក៏មិនហ៊ានបួរផ្ដាច់គេទេ ក៏ដណ្ដឹងទៅគេស្រលាញ់ក៏នៅភូមិចានោម ទៅរកស៊ីនៅថៃបាត់ហើយ បានកូន០១កូនប្រុស អាហ្នឹងរាមច្បង ។ អាទី០២ ស្រីទើបតែការនៅខែស្រាធមោខែដល្កុនខ្ញុំការកូនទី០២ ។ នៅកូនទី០៣ និងកូនទី០៤ នៅលីវ ។

ពៅដារ៉ា ៖ ០២នាក់ក្រោយធ្វើអី?

និប ៖ មិនមានធ្វើអីទេ ។ មួយទៅបើកអាត្រាកនៅសៀមរាបស៊ីឈ្នួលគេ ប្អូនស្រីពៅគេនេះមីបងទើបតែការនេះវានាំទៅថៃជាមួយ ។

ពៅដារ៉ា ៖ មីងមានដែលប្រាប់ពីរឿងរ៉ាវដែលមីងធ្វើការនៅសម័យខ្មែរក្រហមហ្នឹងទេ?

និប ៖ ខ្ញុំប្រាប់អាកូនទី០៣ អាស្ដាប់ណាស់រហូតដល់ម៉ែនិយាយទៀតទៅចង់ស្ដាប់ថាប្រវត្តិហ្នឹងកម្សត់យ៉ាងណា ។ បើប្រជាជនមកពីទីក្រុងភ្នំពេញវិញ មិនដែលស្គាល់ជន្លេទេនៅអូរលៀសព្រៃមាន់ហ្នឹង ទឹកហូរអញ្ចឹងជន្លេវាចេញធំៗប៉ុណ្ណេះយកជន្លេយកទៅស្រុះមិនដែលស្គាល់ស្លឹកគ្រៃទេ ។ ខ្ញុំកូនគុងសីខ្ញុំប្រាប់តែយាយឯងទេស្អាតៗ ។

ពៅដារ៉ា ៖ ឈ្មោះអី?

និប ៖ មិនស្គាល់ទេ ទោះបីជាគេប្រាប់ក៏ខ្ញុំភ្លេចអស់ ។ ខ្ញុំហូបជន្លេហើយមានប្រុសស្អាតៗមកពីទីក្រុងភ្នំពេញដែលគេជម្លៀសមកហ្នឹង គ្នាមិនដែលមានអីហូបទេគ្នាក៏ស្គមៗ យូរៗទៅបាន០១ឆ្នាំអីជួបគ្នាម្ដងក៏ស្គាល់ទំនាក់ទំនងគ្នាទៅ ហើយស្គមៗធំតែក្បាលជង្គង់គេក៏គ្មានបែកខ្ញុំ

ខ្ញុំក៏គ្មានអីចែកគេដែរ ។ ធំតែក្បាលជន្លង់ទេ ខ្លះក៏ងាប់ទៅ ទៅពេទ្យៗក៏គ្មានអីដែរមានតែបបរភាវទៀត គ្មានទេថ្នាំសម្បូរតែរាក ។

ពៅដារ៉ា : នៅជំនាន់នោះ?

និប : ចាស៎!

ពៅដារ៉ា : ពេលមីងនិយាយប្រាប់វាអញ្ចឹង វាមានដូរស់ប្ដូរឥរិយាបថអាណិតមីងអីទេ?

និប : វាថាការហូបចុករបស់ខ្ញុំសព្វថ្ងៃដូចដែលម៉ែឯងនិយាយកាលនៅសម័យអាពត បើខ្ញុំតាមមើលទៅដូចជាយ៉ាប់មិនស៊ូរស់ដូចខ្ញុំពីដើមទេ ។ អាកូនក្មេងសព្វថ្ងៃនេះវាហូបរើសណាស់ បើខ្ញុំវិញមិនរើសបើមិនតស៊ូមានតែស្លាប់ ។ បើឪពុកខ្ញុំគាត់គ្រាន់តែនិយាយក៏ងាប គាត់ថាអញនិយាយងាប់លួជាង បើរស់មិនបានអីហូប ។

ពៅដារ៉ា : ខ្ញុំដូចជាមិនមានអីទៀតទេ ហើយខ្ញុំក៏អរគុណអ្នកមីងច្រើនហើយដែលបានផ្ដល់ព័ត៌មាននេះ ហើយយើងអាចយកព័ត៌មាននេះទៅប្រើប្រាស់ទៅថ្ងៃមុខទៀត កាលណាគេចង់ក្រងជាប្រវត្តិសាស្ត្រ ។

និប : ប៉ុនថាខ្ញុំពិការតាំងពីនោះឯង ព្រោះពិការនេះយូរហើយប្រហែលជា១០ឆ្នាំហើយ រែកទឹកក៏រែកមិនកើត គ្រាន់តែដាំបាយឲ្យប៉ាគាត់ហូប ហើយកូនចៅចេញទៅរកអស់ ។ មិនមានអីទេដូចជាស្រែក្ដីមានតែ០១កន្លែង០២រៅ០៣រៅឲ្យរកប្រាក់ទៅវិញអត់ទេ ។

ពៅដារ៉ា : ធ្វើបានទេរាល់ថ្ងៃ?

និប : បាន ។ ដីមានចំនួនទាំងអស់មិនទាន់ចែកកូនចៅមាន០២ហិចតាទេ បានគ្រាន់តែមាហូបជូនឆ្នាំណាដែលកើតវាបាន៣០ប៉ាវ០១ហិចតា បើឆ្នាំណាដែលវាលិចអស់វាក៏យ៉ាប់ដែរ ។

ពៅដារ៉ា : អញ្ចឹងពួកខ្ញុំអរគុណមីងច្រើនដែលបានផ្ដល់ព័ត៌មានពីខាងដើមមោ ។